ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,

Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN Saray**
ជាតំណាងទី ១ និង
ជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
ជាតំណាងទី ២ និង
ជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហិរញ្ញិក
និងជានាយក **CCPCR**

លោក **យៀង វណ្ណា**
**Mr. YEANG Vanna**
ប្រធាន **KKKHRA**

លោក **ជីវ យូម៉េង**
**Mr. CHIV You Meng**
ប្រធាន **KYA**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**
នាយិកា **LAC**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
ប្រធាន **PDP Center**

លោក **ទូច ទុម្ព**
**Mr. TOUCH Tum**
នាយក **VIGILANCE**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

នាយិកា **CWCC**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**
**ឥស្សរជន**

លោក **សឺន សែត**
**Mr. SEN Set**
**ឥស្សរជន**

# របាយការណ៍

# ស្តីពី

# លទ្ធផលនៃការវាយតម្លៃរបស់យុវជនទៅលើការបំពេញរបស់រាជរដ្ឋាភិបាលកម្ពុជា ឬ គណបក្សជាប់ឆ្នោតក្នុងការអនុវត្ត "កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"

*មជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន, រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៧*

**ការវាយតម្លៃរបស់ម្ចាស់ឆ្នោតជាយុវជនចំនួន ១១០ នាក់ ក្នុងនោះមានយុវតីចំនួន ៤៤ នាក់ ស្មើនឹង ៤០%** ដែលបានចូលរួមក្នុងវេទិការៀបចំឡើងដោយ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល សហការជាមួយ ក្រុមប្រឹក្សាយុវជនកម្ពុជា សមាគមយុវជនខ្មែរ និងកម្មវិធី**អភិវឌ្ឍន៍ធនធានយុវជន** បានធ្វើឡើង បន្ទាប់ពីមានការពិភាក្សានិងស្តាប់នូវរបាយការណ៍ជាក់ស្តែងខ្លះ របស់វាគ្មិនចំនួន ៣ រូប ជាអ្នកតំណាងរាស្ត្រចំនួន ២ រូប និងនាយកអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) អំពីការអនុវត្ត "កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"។ ការវាយតម្លៃបានផ្តោតទៅលើ ៤ ចំណុចចម្បងៗ ដោយមានការដាក់ពិន្ទុពីអ្នកចូលរួមវេទិកា - **ពិន្ទុនៅចន្លោះពី ១: មិនពេញចិត្តសោះ ទៅ ៥: ពេញចិត្តខ្លាំងណាស់**។ ចំណុចទាំង ៤ នោះ រួមមាន:

(១)- *ការបញ្ចប់ និងដាក់បញ្ជូនទៅរដ្ឋសភានូវច្បាប់* ដូចជា: លក្ខន្តិកៈនៃអង្គចៅក្រម ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ... និងច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃអាជ្ញាសាលា

(២)- *ការបង្កើតតុលាការពិសេស និងតុលាការគំរូដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាព* ដូចជា តុលាការពាណិជ្ជកម្ម តុលាការសម្រាប់អនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល

(៣)- *ការបង្កើនសមត្ថភាព និងការទទួលខុសត្រូវរបស់ចៅក្រម...និងចៅក្រមមានអាយុលើសពី ៦០ឆ្នាំ គួរតែចូលនិវត្តន៍។ ការបណ្តុះបណ្តាល* ក្រឡាបញ្ជី តុលាការ សាការី និងនគរបាលយុត្តិធម៌ និង

(៤)- *ផ្តល់ជំនួយផ្នែកច្បាប់ឱ្យដល់ជនក្រីក្រ និងបង្កើនយន្តការសម្រាប់ដោះស្រាយទំនាស់* ក្រៅប្រព័ន្ធតុលាការ។

(១) - ចំពោះ*ការបញ្ចប់ និងដាក់បញ្ជូនទៅរដ្ឋសភានូវច្បាប់ ដូចជា: លក្ខន្តិកៈនៃអង្គចៅក្រម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអង្គតុលាការ ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃសាការីសាធារណៈ និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាសាលា*អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ**២,៤៣**។ ពិន្ទុនេះសំដៅទៅកម្រិត**ពេញចិត្តត្រឹមតិចតួច បំផុត**។ ក្នុងនោះអ្នកផ្តល់ពិន្ទុ១(មិនពេញចិត្តសោះ)មាន ៦% អ្នកផ្តល់ពិន្ទុ២(ពេញចិត្តតិចតួចបំផុត)មាន ៥៧% អ្នកផ្តល់ពិន្ទុ ៣ (ពេញចិត្តគួរសម) មាន ២៥% អ្នកផ្តល់ពិន្ទុ ៤ (ពេញចិត្តច្រើន) មាន ១១% និងអ្នកផ្តល់ពិន្ទុ ៥ (ពេញចិត្តខ្លាំងណាស់) មានតែ ១% ប៉ុណ្ណោះ។

ការពិភាក្សា និងរបាយការណ៍ជាក់ស្តែងបានរកឃើញថា ទោះបីមានការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងមានការអនុម័តច្បាប់ និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់រហូតដល់ **៥៨** ច្បាប់ និងអនុសញ្ញា សន្ធិសញ្ញា និងកតិកាសញ្ញាមួយចំនួនទៀតគិតត្រឹម**ខែកញ្ញា ឆ្នាំ២០០៧**នេះក៏ដោយ ក៏ក្នុងចំណោមច្បាប់ចំនួន ៨ ដែលសំខាន់ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ គឺមានតែ *ច្បាប់ស្តីពីក្រមនីតិវិធីរដ្ឋប្បវេណី* និង *ក្រមនីតិវិធីព្រហ្មទណ្ឌ* ប៉ុណ្ណោះដែលត្រូវបានសភាអនុម័ត។ ចំណែកក្រមរដ្ឋប្បវេណីត្រូវបានគណៈកម្មការជំនាញរដ្ឋសភាពិនិត្យមើលរួចហើយ នៅតែរង់ចាំការ-ពិភាក្សា និងអនុម័តនៅក្នុងសភាពេញអង្គ ហើយក្រមព្រហ្មទណ្ឌកំពុងតែត្រូវបានពិភាក្សានៅគណៈកម្មការជំនាញរបស់សភា។ ចំណែកឯច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម កំពុងស្ថិតនៅក្រោមការពិនិត្យមើលដោយក្រុមអ្នកច្បាប់នៃទីស្តីការគណៈ-រដ្ឋមន្ត្រី ហើយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គតុលាការត្រូវបានព្រាងរួចហើយ តែមិនទាន់បញ្ជូនទៅរដ្ឋ-សភានៅឡើយ។ ច្បាប់ស្តីពី*ការប្រព្រឹត្តិទៅនៃសាការីសាធារណៈ* មិនទាន់ត្រូវបានបង្កើតនៅឡើយ តែមានអនុក្រឹត្យ។ ចំណែកច្បាប់ផ្សេងៗទៀតមិនមានព័ត៌មានទេ។ លោក **សុក សំអឿន** ប្រធានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានឱ្យដឹងថា ច្បាប់ទាំងនេះត្រូវបានព្រាងរួចរាល់អស់ហើយ **តែនៅរង់ចាំការសម្រេចរបស់អ្នកនយោបាយ**។ អ្នកតំណាង-រាស្ត្រ **ម៉ោញ សាផាន** មណ្ឌលកំពង់ចាម បានឱ្យដឹងថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានសន្យាថា នឹងបញ្ជូនច្បាប់ទាំងនេះមកកាន់រដ្ឋសភាឱ្យបានឆាប់ តែមិនដឹងពេលណានោះទេ។

(២) - ***ចំពោះការបង្កើតតុលាការពិសេស និងតុលាការគំរូ ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាព*** ដូចជា *តុលាការពាណិជ្ជកម្ម តុលាការសម្រាប់អនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល* អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ **២,២៣**។ ពិន្ទុនេះសំដៅទៅកម្រិត **ពេញចិត្តត្រឹមតិចតួចបំផុត**។ ក្នុងនោះអ្នកផ្តល់ពិន្ទុ ១ (មិនពេញចិត្តសោះ) មាន ២៥% អ្នកផ្តល់ពិន្ទុ ២ (ពេញចិត្តតិចតួចបំផុត) មាន ៤១% អ្នកផ្តល់ពិន្ទុ ៣ (ពេញចិត្តគួរសម) មាន ២២% អ្នកផ្តល់ពិន្ទុ ៤ (ពេញចិត្តច្រើន) មាន ៩% និងអ្នកផ្តល់ពិន្ទុ ៥ (ពេញចិត្តខ្លាំងណាស់) មាន ៣%។

ការពិភាក្សា និងរបាយការណ៍ជាក់ស្តែងបានរកឃើញថា រហូតមកដល់ពេលនេះមិនមានស្ថាប័នតុលាការណាមួយរៀបរាប់ខាងលើត្រូវនេះបានបង្កើតឡើងនៅឡើយទេ។ មានការសាកល្បងបង្កើតតុលាការគំរូនៅខេត្តកណ្តាល។ តុលាការ

ខេត្ត/ក្រុងចំនួន ២១ សាលាឧទ្ធរណ៍ ១ និងតុលាការកំពូល ១ ដែលមានចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន ២២៦ រូប[1] នៅទូទាំងប្រទេសត្រូវដោះស្រាយរឿងក្តីទាំងអស់រួមទាំងរដ្ឋបាល ពាណិជ្ជកម្ម និងកាត់ក្តីអនីតិជន។ ជាលទ្ធផល តុលាការអាចដោះស្រាយសំណុំរឿងក្នុងមួយឆ្នាំៗតែ១២.០០០ករណីប៉ុណ្ណោះ ដែលបណ្តាលឱ្យមានសំណុំរឿងជាច្រើន មិនត្រូវបានដោះស្រាយទាន់ពេលវេលា។ ក្នុងឆ្នាំ ២០០៥ ៤០% នៃករណីសង្ស័យពីបទឧក្រិដ្ឋ ត្រូវបានឃុំខ្លួនលើសរយៈពេលឃុំខ្លួនអតិបរមា (៦ ខែ) មុនការកាត់ក្តីតាមផ្លូវច្បាប់ យោងតាមរបាយការណ៍ អាដហុក ឆ្នាំ ២០០៦។ ការបង្កើតតុលាការពាណិជ្ជកម្មជាបន្ទាន់ ពិតជាមានសារៈសំខាន់ខាងសេដ្ឋកិច្ច និងការវិនិយោគ ដែលឆ្លើយតបទៅនឹងការតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO)និងការទុកចិត្តរបស់ផ្សារភាគហ៊ុន។ ទន្ទឹមនឹងអវត្តមានតុលាការអនីតិជន កុមារក៏ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ កាន់តែច្រើនឡើង។ របាយការណ៍របស់លីកាដូ ឆ្នាំ២០០៧ បានពណ៌នាស្ថានភាពកុមារក្នុងពន្ធនាគារប្រទេសកម្ពុជាថា អាក្រក់ មានចំនួនអ្នកទោសណែនណាន់ គ្មានអនាម័យ។ ជាងនេះទៅទៀត ប្រហែល ៤០% នៃកុមារជាប់ពន្ធនាគារត្រូវបានឃុំខ្លួនជាមួយមនុស្សពេញវ័យ ហើយពួកគេទទួលបានការអប់រំ ការបណ្តុះបណ្តាល និងការតំណាងតាមផ្លូវច្បាប់ដ៏តិចតួច។

(៣)- *ការបង្កើនសមត្ថភាព និងការទទួលខុសត្រូវរបស់ចៅក្រម...និងចៅក្រមមានអាយុលើសពី ៦០ឆ្នាំ គួរតែចូលនិវត្តន៍។* ចំពោះ*ការបណ្តុះបណ្តាលក្រឡាបញ្ជីតុលាការ សាការី និងនគរបាលយុត្តិធម៌* អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ **២,៥២**។ ពិន្ទុនេះសំដៅទៅកម្រិត**ពេញចិត្តគួរសមខ្លះ**។ ក្នុងនោះ អ្នកផ្តល់ពិន្ទុ ១ (មិនពេញចិត្តសោះ) មាន ១៦% អ្នកផ្តល់ពិន្ទុ ២ (ពេញចិត្តតិចតួចបំផុត) មាន ៤១% អ្នកផ្តល់ពិន្ទុ ៣ (ពេញចិត្តគួរសម) មាន ២៦% អ្នកផ្តល់ពិន្ទុ ៤ (ពេញចិត្តច្រើន) មាន ១០% និងអ្នកផ្តល់ពិន្ទុ ៥ (ពេញចិត្តខ្លាំងណាស់) មាន ៧%។

ការពិភាក្សា និងរបាយការណ៍បានរកឃើញថា មានការបង្កើតសាលាភូមិន្ទចៅក្រម រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សាលាបណ្តុះបណ្តាលក្រឡាបញ្ជីតុលាការ អាជ្ញាសាលា និងមន្ទីរសាការី ទោះបីយ៉ាងណា ក៏នៅតែជួបកង្វះខាតចៅក្រម។ ក៏មានការបណ្តុះបណ្តាលនគរបាលយុត្តិធម៌ផងដែរ ក៏ប៉ុន្តែលោក **សុក សំអឿន** បានឱ្យដឹងថារយៈពេលនៃការបណ្តុះ-បណ្តាលមានរយៈពេលខ្លី។ ក្រមនីតិវិធីព្រហ្មទណ្ឌដែលទើបតែចូលជាធរមាននាពេលថ្មីៗនេះ តម្រូវឱ្យមានចៅក្រម ៣ រូប ធ្វើអធិបតីលើបទឧក្រិដ្ឋ ខណៈដែលខេត្តខ្លះដូចជា ខេត្តព្រះវិហារ មណ្ឌលគិរី រតនៈគិរី និងក្រចេះ មានចៅក្រមតែ ២ រូបប៉ុណ្ណោះ។ តាមសារព័ត៌មាន ឌឹឃេមបូឌា ដេលី *(១៣ ខែកញ្ញា ឆ្នាំ ២០០៧ កង្វះខាតចៅក្រម បង្អាក់ដំណើរដ៏យឺតយ៉ាវឆ្ពោះទៅរកយុត្តិធម៌)* បានឱ្យដឹងថា ចៅក្រម និងព្រះរាជអាជ្ញាចំនួន ៥៥ រូប នឹងបញ្ចប់ការសិក្សានៅឆ្នាំ ២០០៨ និង ៦៣ រូបទៀត នឹងបញ្ចប់នៅឆ្នាំ ២០០៩។

---

១ ចំនួនចៅក្រមនេះគឺស្រង់ចេញពី *ឌឹឃេមបូឌា ដេលី (១៣ ខែកញ្ញា ឆ្នាំ ២០០៧)* ទំព័រទី ១, ២: ប្រាក់ ចាន់ថុលៈ កង្វះខាតចៅក្រម បង្អាក់ដំណើរដ៏យឺតយ៉ាវឆ្ពោះទៅរកយុត្តិធម៌។

អង្គវេទិកាក៏បានលើកឡើងផងដែរថា មានចៅក្រមមួយចំនួនមិនឯករាជ្យ ហើយងាយនឹងប្រព្រឹត្តអំពើពុករលួយ។ អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** មណ្ឌលសៀមរាប បានលើកឡើងថា មានពាក្យបណ្តឹងរបស់ពលរដ្ឋខ្លះ ត្រូវបានតុលាការផ្អើបទុកចោលរាប់ខែរហូតដល់រាប់ឆ្នាំ។ បើទោះបីមានការរកឃើញថាចៅក្រម និងព្រះរាជអាជ្ញាមួយចំនួនបានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើពុករលួយ ហើយរាជរដ្ឋាភិបាលបានចោទប្រកាន់ចំពោះបញ្ហានេះ ហើយថាប្រើប្រាស់កណ្តាប់ "ដៃដែក" ក៏អ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន** បានថ្លែងថា ការដាក់ទណ្ឌកម្មចៅក្រមដែលធ្វើខុស មិនទាន់សមស្របទៅនឹងកំហុសរបស់ចៅក្រម [និងព្រះរាជអាជ្ញា] ឡើយ ដែលភាគច្រើន គឺគ្រាន់តែជាការផ្លាស់មុខតំណែង ឬផ្លាស់ពីកន្លែងមួយទៅកន្លែងមួយប៉ុណ្ណោះ។ ថ្មីៗនេះ តំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានរកឃើញថា ការតែងតាំងការផ្លាស់ប្តូរចៅក្រមខ្លះ មិនស្របទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ឬមិនយោងតាមសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ តែបែរជាយោងទៅតាមសំណើសុំរបស់ស្ថាប័ននីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាលទៅវិញ។

របាយការណ៍របស់ អាដហុក ស្តីពីស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៦ បានឱ្យដឹងថា "យុត្តិធម៌ត្រូវបានគេបន្ទលក់ដូរទៅឱ្យជនណាដែលអាចមានប្រាក់ទិញវា"។ របាយការណ៍នេះបានរៀបរាប់ពីប្រព័ន្ធតុលាការថា ក្លែងក្លាយ មានការសូកប៉ាន់ និងមានភាពរួចទោស ដែលធ្វើឱ្យលទ្ធភាពទទួលបានយុត្តិធម៌ត្រូវបានរារាំងយ៉ាងខ្លាំង។ របាយការណ៍ដដែលនេះ បានឱ្យដឹងទៀតថា មានបញ្ហាចោទធ្ងន់ធ្ងរក្នុងការមិនបានអនុវត្តតាមតម្រូវការផ្លូវច្បាប់សំរាប់ការកាត់ក្តីដ៏យុត្តិធម៌មួយ។ បញ្ហាទាំងនេះរួមមាន ការមិនបានអនុវត្តតាមរយៈពេលឃុំខ្លួនអតិបរមាមុនការកាត់ក្តីតាមផ្លូវច្បាប់ (ក្នុងឆ្នាំ ២០០៥ មាន ៤០% នៃជនសង្ស័យនៃសំណុំរឿងឧក្រិដ្ឋបានត្រូវឃុំខ្លួនយូរជាងរយៈពេល៦ខែ) ការធ្វើទារុណកម្ម ដែលត្រូវបានគេចោទប្រកាន់នៅក្នុងដំណាក់កាលនៃការសួរចម្លើយ(ក្នុងឆ្នាំ២០០៥ មានម្នាក់ក្នុងចំណោមជនសង្ស័យ ៣ នាក់ក្នុងករណីឧក្រិដ្ឋ ចោទប្រកាន់ថាពួកគេត្រូវបានគេធ្វើទារុណកម្ម) ការមិនតម្រូវឱ្យសាក្សីផ្តល់ចម្លើយផ្ទាល់មាត់នៅក្នុងតុលាការ (ក្នុងឆ្នាំ ២០០៥ សាក្សីបានឡើងមកបំភ្លឺតែក្នុង ១៦% នៃករណីទាំងអស់តែប៉ុណ្ណោះ) ជាធម្មតា ជនជាប់ចោទមិនត្រូវបានចៅក្រម អនុញ្ញាតឱ្យហៅសាក្សីមកជួយបំភ្លឺ ការមិនផ្តល់នូវមេធាវីដើម្បីធានាបាននូវការកាត់ក្តីដ៏យុត្តិធម៌មួយ (ក្នុងឆ្នាំ២០០៥ ចុងចោទ ៤៦% គ្មានអ្នកតំណាងផ្លូវច្បាប់) ការកាត់ក្តីប្រព្រឹត្តទៅក្នុងពេលជនជាប់ចោទអវត្តមាន ហើយនិងការកាត់ក្តីឆាប់រហ័សពេកដែលមិនអាចមានភាពយុត្តិធម៌តាមរយៈដំណើរការតុលាការបានឡើយ (ក្នុងឆ្នាំ ២០០៥ ប្រហែលជាពាក់កណ្តាលនៃសំណុំរឿងឧក្រិដ្ឋត្រូវបានបញ្ចប់ក្នុងរយៈពេលតិចជាង ៣០ នាទី ហើយសមាគមអាដហុក បានឱ្យដឹងថាតួលេខនេះ សំរាប់ឆ្នាំ ២០០៦ គឺកាន់តែខ្ពស់ទៅទៀត)។

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានកត់សម្គាល់ក្នុងរបាយការណ៍សង្កេតតុលាការឆ្នាំ ២០០៦ ថា ការបញ្ជូន និងការទទួលឯកសារតុលាការ (ដូចជាដីកាកោះ ដីកានាំខ្លួន ដីកាឃុំខ្លួន ឬ ដីកាដោះលែង និងសាលក្រម) ជាកង្វល់មួយទៀត ដែលកម្មវិធីសង្កេតការណ៍តុលាការបានកត់សម្គាល់ឃើញ។ ឧទាហរណ៍ សាលក្រមជាលាយល័ក្ខណ៍អក្សរ ត្រូវតែសរសេរភ្លាមៗបន្ទាប់ពីជំនុំជម្រះរួច (ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥)។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ការសរសេរសាលក្រមនេះ អាចប្រើពេលច្រើនថ្ងៃ ឬអាចទៅដល់ច្រើនខែក៏មាន។ ទង្វើនេះប៉ះពាល់ដល់លទ្ធភាពរបស់គូភាគី ក្នុងការធ្វើ

បណ្តឹងឧទ្ធរណ៍ ដែលត្រូវធ្វើក្នុងរយៈពេល ២ ខែ បន្ទាប់ពីការប្រកាសសាលក្រមដោយផ្ទាល់មាត់។ របាយការណ៍នេះ ក៏ឱ្យដឹងដែរថា ការពន្យារពេលក៏កើតមានផងដែរ ចំពោះការបើកសវនាការឧទ្ធរណ៍ ដោយសារការយឺតយ៉ាវក្នុងការបញ្ជូនឯកសារពីតុលាការថ្នាក់ក្រោមទៅសាលាឧទ្ធរណ៍។ ការបញ្ជូនឯកសារមួយចំនួន ត្រូវចំណាយពេលអស់ដល់ទៅពីរឆ្នាំ។ ការយឺតយ៉ាវនេះ ផ្ទុយនឹងសារាចរ ដែលចេញដោយក្រសួងយុត្តិធម៌នៅឆ្នាំ ១៩៩៥ ដែលកំណត់ថា តុលាការថ្នាក់ក្រោមត្រូវបញ្ជូនឯកសារក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីមានបណ្តឹងតវ៉ា។

៤- ចំពោះ *ការផ្តល់ជំនួយផ្នែកច្បាប់ឱ្យដល់ជនក្រីក្រ និងការបង្កើនយន្តការសម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ* អ្នកចូលរួមវេទិកាជាយុវជនបានឱ្យពិន្ទុ **២,៤២**។ ពិន្ទុនេះសំដៅទៅកម្រិតពេញចិត្តត្រឹមតិចតួចបំផុត។ ក្នុងនោះអ្នកផ្តល់ពិន្ទុ ១ (មិនពេញចិត្តសោះ) មាន ២១% អ្នកផ្តល់ពិន្ទុ ២ (ពេញចិត្តតិចតួចបំផុត) មាន ៣៧% អ្នកផ្តល់ពិន្ទុ ៣ (ពេញចិត្តគួរសម) មាន ២៨% អ្នកផ្តល់ពិន្ទុ ៤ (ពេញចិត្តច្រើន) មាន ៩% និងអ្នកផ្តល់ពិន្ទុ ៥ (ពេញចិត្តខ្លាំង ណាស់) មាន ៥% ប៉ុណ្ណោះ។

ការពិភាក្សា និងរបាយការណ៍បានរកឃើញថា មានយន្តការដោះស្រាយ និងផ្សះផ្សាទំនាស់ក្រៅប្រព័ន្ធតុលាការ ដូចជា មានការបង្កើតអាជ្ញាធរជាតិផ្សេងៗ និងសេវាកម្មយុត្តិធម៌ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ស្រុកនៅក្នុងខេត្តកំពង់ស្ពឺ ទោះបីយ៉ាងណាអង្គវេទិកាបានរកឃើញថា អាជ្ញាធរជាតិដើម្បីដោះស្រាយទំនាស់ខ្លះគឺស្ថិតនៅក្រោមរាជរដ្ឋាភិបាល ហើយមិនទាន់ឯករាជ្យ។ មានគំរូនៃយន្តការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីដោះ-ស្រាយវិវាទការងារឱ្យដឹងថា ក្នុងឆ្នាំ២០០៦ មានសំណុំរឿងដែលបានដាក់ចំនួន ១២០ ហើយមានចំនួន ១១០ ត្រូវបានដោះស្រាយ។ អ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន** មណ្ឌលកំពង់ចាមបានឱ្យដឹងថា មានភាពចម្រូងចម្រាសមិនទាន់ដោះ-ស្រាយ **រវាងសេចក្តីជូនដំណឹង (ស.ជ.ណ) របស់រាជរដ្ឋាភិបាល និងសាលក្រមរបស់តុលាការ** ទៅលើរឿងក្តីតែមួយ។

ជាមួយគ្នានេះដែរ របាយការណ៍ស្ថានភាពសិទ្ធិមនុស្សឆ្នាំ ២០០៦ (អាដហុក ឆ្នាំ ២០០៧) បានឱ្យដឹងថាក្នុងមួយឆ្នាំៗ ក្រុមប្រឹក្សាឃុំ/សង្កាត់នៅទូទាំងប្រទេស ទទួលករណីវិវាទ ៤០.០០០ ករណី តែក្រុមប្រឹក្សាឃុំ/សង្កាត់អាចធ្វើបានត្រឹមតែការសម្រុះសម្រួលប៉ុណ្ណោះ និងខ្វះយន្តការច្បាប់ ដើម្បីអនុវត្តសេចក្តីសម្រេចចិត្ត ដែលពួកគេធ្វើឡើង។ មានការពង្រឹងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ និងជនរងគ្រោះ នៃអំពើរំលោភសិទ្ធិ (ដីធ្លី) ហើយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយក៏បានជម្រុញ និងបង្កើនការផ្សព្វផ្សាយច្បាប់បានយ៉ាងច្រើន។

ជាសរុបល្បឿននៃការបំពេញ និងការអនុវត្តការសន្យា "កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" មានលក្ខណៈយឺតយ៉ាងខ្លាំង។ ពិន្ទុជាមធ្យមនៃការបំពេញរបស់រាជរដ្ឋាភិបាល ឬគណបក្សជាប់ឆ្នោតក្នុង "កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ដែលត្រូវបានផ្តល់ឱ្យដោយយុវជនក្នុងវេទិកានេះគឺ ២,៤។ ពិន្ទុនេះមានន័យថា កម្រិតពេញចិត្តនៅត្រឹម "តិចតួច

បំផុត"។ មានតែការបង្កើនសមត្ថភាព និងការទទួលខុសត្រូវរបស់ចៅក្រមតាមរយៈការបណ្តុះបណ្តាលទេ ដែលត្រូវបានផ្តល់ពិន្ទុច្រើនជាងមធ្យម គឺ **២.៥២**។ នេះអាចបកស្រាយថាមានកម្រិតពេញចិត្តគួរសម។

អ្នកចូលរួមជាយុវជន បានផ្តល់យោបល់ទៅលើអាទិភាពនៃវិស័យកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការដើម្បីឱ្យរាជរដ្ឋាភិបាល ឬគណបក្សនយោបាយជាប់ឆ្នោតខិតខំបន្តអនុវត្តការសន្យា ហើយគណបក្សចូលរួមប្រកួតប្រជែងការបោះឆ្នោតជាតិឆ្នាំ ២០០៨ ក៏គួរយកចិត្តទុកដាក់យកយោបល់នេះ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន។ ចំណុចជាអាទិភាពទាំងនោះមុនបញ្ចប់អាណត្តិរបស់ខ្លួនមានដូចជា:

- *ត្រូវបង្កើតច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គការចាត់តាំង និងការប្រព្រឹត្តិទៅរបស់តុលាការ និងការធ្វើវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានានូវឯករាជ្យភាពនិងសុវត្ថិភាពរបស់ចៅក្រម។*
- *ត្រូវពង្រឹងការអនុវត្តច្បាប់ ដូចជាចៅក្រមដែលត្រូវបានដកពីតួនាទី ត្រូវតែមានការស៊ើបអង្កេត និងដាក់ពិន័យឱ្យស្របទៅនឹងកំហុស ហើយកុំឱ្យមានការតែងតាំងចៅក្រមដែលធ្វើខុសឱ្យកាន់មុខតំណែងជាថ្មី*
- *ត្រូវបង្កើតតុលាការពាណិជ្ជកម្ម ដើម្បីទាក់ទាញអ្នកវិនិយោគ និងសម្រួលដល់ការងាររបស់តុលាការខេត្ត/ក្រុង*
- *ត្រូវពង្រឹងសេវាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។*

ជាសរុប ចំណុចសំខាន់ទាំងអស់ដែលមានក្នុងកម្មវិធីនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅតែមានតម្លៃសម្រាប់គណបក្សនយោបាយដើម្បីធ្វើជាកម្មវិធីនយោបាយរបស់ខ្លួនក្នុងការប្រកួតប្រជែងការបោះឆ្នោតខាងមុខ ប៉ុន្តែគណបក្សនយោបាយទាំងនោះ ត្រូវបញ្ជាក់អំពីរបៀប និងល្បឿនក្នុងការអនុវត្ត។


*សម្រាប់ព័ត៌មានលម្អិតសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១
- លោក **កុយ ច័ន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១


*បេសកកម្មទី ២ ក្នុងចំណោមបេសកកម្មទាំងពីររបស់ ខុមហ្វ្រែល គឺ "ជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះសាធារណជន យល់យ៉ាងច្បាស់អំពីដំណើរការលទ្ធិប្រជាធិបតេយ្យ មិនត្រឹមតែ មុនពេលបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រោយ និងចន្លោះពេលបោះឆ្នោតទៀតផង។ ដើម្បីសំរេចបេសកកម្មនេះ ខុមហ្វ្រែល រៀបចំការអប់រំ និងវេទិកាសាធារណៈ ក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសម្រេចនានា។ លើកទឹកចិត្តការចូលរួមការតស៊ូមតិ បញ្ចុះបញ្ចូល ដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោត ដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត និងចុងក្រោយ ដោយផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័សដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលម្អៀង និងមិនប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តការងាររបស់មន្ត្រីជាប់ឆ្នោត។"*